**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២២៤ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈ-កម្មាធិការប្រតិបត្តិនិងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- បានឃើញអនុក្រឹត្យលេខ ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាបំណេះទូទៅ
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្ដីពី ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- បានឃើញអនុក្រឹត្យលេខ ១៤៣ អនុក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១**.-

ត្រូវបានបង្កើត "**មូលនិធិហិរញ្ញប្បទានគាំពារសង្គម**" សរសេរជាអក្សរកាត់ **ម.គ.ស**. ដើម្បីពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហិរញ្ញប្បទានប្រព័ន្ធគាំពារសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២**.-

**ម.គ.ស**. មានវិសាលភាពអនុវត្តចំពោះរបបសន្តិសុខសង្គម និងកម្មវិធីជាតិជំនួយសង្គម មានជាអាទិ៍ៈ

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់ក្នុងករណីបន្ទាន់ និងកម្មវិធីជាតិជំនួយសង្គមផ្សេងៗទៀត ក្នុងក្របខណ្ឌកញ្ចប់កម្មវិធីគ្រួសារ
- កម្មវិធីផ្ដល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- កម្មវិធីផ្ដល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករ-និយោជិតជាស្ត្រី នៅពេលសម្រាលកូន
- ប្រព័ន្ធកំណត់អត្តសញ្ញាណប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋគោលដៅសម្រាប់កម្មវិធីជាតិ និងរបបក្នុងប្រព័ន្ធគាំពារសង្គម
- កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមផ្សេងទៀត តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី២

## ប្រភពធនធាន

**មាត្រា៣**.-

**ម.គ.ស**. មានប្រភពធនធានពីៈ

- វិភាគទានដំបូងរបស់រដ្ឋ
- ថវិការដ្ឋដែលវិភាជប្រចាំឆ្នាំសម្រាប់ហិរញ្ញប្បទានកម្មវិធីជាតិ និងរបប ដូចមានចែងក្នុងមាត្រា២
- ហិរញ្ញប្បទានសហប្រតិបត្តិការ និងហិរញ្ញប្បទានពីប្រភពស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៣
## ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងមូលនិធិ

**មាត្រា៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ទទួលខុសត្រូវក្នុងការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែង **ម.គ.ស.** ដោយមានប្រធានគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមបំពេញតួនាទីជាលេខាធិការដ្ឋាន។

**មាត្រា៥.-**

ធនធានហិរញ្ញវត្ថុរបស់ **ម.គ.ស.** ត្រូវរក្សាទុកក្នុងគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ឬគណនីនៅធនាគារជាតិនៃកម្ពុជា។ **ម.គ.ស.** អាចមានគណនីនៅធនាគារពាណិជ្ជ ដើម្បីប្រើប្រាស់ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ជំពូកទី៤
## ការរៀបចំ និងការអនុវត្តថវិកាប្រចាំឆ្នាំ

**មាត្រា៦.-**

កញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ដូចមានកំណត់ក្នុងមាត្រា២ ត្រូវគ្រោងក្នុងក្របខណ្ឌកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ។

ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ត្រូវរៀបចំកម្មវិធីឧបត្ថម្ភប្រាក់សម្រាប់បើកផ្តល់តាមកម្មវិធីចំណាយ និងស្របតាមឥណទានថវិកាប្រចាំឆ្នាំរបស់ខ្លួន។

ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ទៅតាមតម្រូវការចំណាយជាក់ស្តែង ដើម្បីរក្សាទុកក្នុងគណនីប្រាក់បញ្ញើរបស់ **ម.គ.ស.**។

**ម.គ.ស.** ត្រូវគ្រប់គ្រងកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម និងចាត់ចែងបើកផ្តល់សម្រាប់ការអនុវត្តកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនីមួយៗ ទៅតាមសំណើរបស់ក្រសួង-ស្ថាប័នដែលទទួលបន្ទុកអនុវត្ត ។

**មាត្រា៧.-**

នីតិវិធីអនុវត្តថវិកាប្រចាំឆ្នាំសម្រាប់កម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ